# សេចក្តីប្រកាសព័ត៌មាន
# យុទ្ធនាការរយៈពេលមួយសប្តាហ៍ចូលរួមប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២២ ក្រោមប្រធានបទ “សារព័ត៌មានក្នុងសម្ពាធប្រព័ន្ធឌីជីថល”

ភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ --- ក្រុមការងារដើម្បីសេរីភាពសារព័ត៌មាន ដែលរួមមានអង្គការ-សមាគមអ្នកសារព័ត៌មាន និងអង្គការសង្គមស៊ីវិលសរុបចំនួន ២៦ស្ថាប័ន បានរួមគ្នារៀបចំជាយុទ្ធនាការតាមបណ្តាញសង្គមរយៈពេលមួយសប្តាហ៍ ក្នុងគោលបំណង ឆ្លុះបញ្ចាំងពីសារៈសំខាន់ និងជំរុញឱ្យមានការចូលរួមពីសាធារណជនក្នុងការលើកកម្ពស់សេរីភាព សារព័ត៌មាននៅក្នុងប្រទេសកម្ពុជា ។

យុទ្ធនាការនេះនឹងចាប់ផ្តើមពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២នេះ ដើម្បីចូលរួមប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២២ ក្រោមប្រធានបទរួម **“សារព័ត៌មានក្នុងសម្ពាធប្រព័ន្ធឌីជីថល”** ។ នៅក្នុងអំឡុងពេលនៃយុទ្ធនាការ សកម្មភាពមួយចំនួននឹងត្រូវបានអនុវត្តដោយបណ្តាស្ថាប័នដែលជាសមាជិក នៃក្រុមការងារ និងអ្នកពាក់ព័ន្ធ ព្រមទាំងការចូលរួមពីសំណាក់សាធារណជនផងដែរ។
សកម្មភាពសំខាន់ៗទាំងនោះរួមមាន ៖

- ការបង្ហោះសារខ្លីៗអំពីសារៈសំខាន់នៃព័ត៌មានចំពោះប្រយោជន៍សាធារណៈ
- ការបង្ហោះវីដេអូស្តីពីសារៈសំខាន់នៃតួនាទីអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ
- កិច្ចពិភាក្សាតាមវិទ្យុ និងបណ្តាញសង្គមលើប្រធានបទពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន
- កិច្ចពិភាក្សាពិសេសនៅថ្ងៃទី២ ខែឧសភា ដែលនឹងមានការអញ្ជើញចូលរួមពីវាគ្មិន ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការជាតិ និងអន្តរជាតិ ដែលធ្វើការពាក់ព័ន្ធនឹងវិស័យសារព័ត៌មានសរុបប្រមាណ ២០០នាក់ផងដែរ។

### សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**អ្នកស្រី ឆន សុគន្ធា** នាយិកានៃនាយកដ្ឋានអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM):០៩៣ ៨៣១ ៩៩០; csokunthea@ccimcambodia.org
**លោក ណុប វី** នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា **(ខេមបូចា):** ០១២ ៥១៩ ២៦១; ed@camboja.net

ក្រុមការងារដើម្បីសេរីភាពសារព័ត៌មាន ដែលបានចូលរួមរៀបចំយុទ្ធនាការនេះរួមមាន៖

១. អង្គការអាក់សិនអេតកម្ពុជា (AAC)
២. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
៣. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៥. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៦. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)
៧. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

៨. បណ្ដាញយុវជនកម្ពុជា (CYN)
៩. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
១០. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
១១. មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
១២. អង្គការសមាគមធាងត្នោត (STT)
១៣. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
១៤. អង្គការតម្លាភាពកម្ពុជា (TIC)
១៥. អង្គការយូណេស្កូ (UNESCO)
១៦. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១៧. អង្គការថែរក្សាភាសាជនជាតិដើមភាគតិច (CIPL)
១៨. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចប្រព័ន្ធ (IDEA)
១៩ មូលនិធិខុនរ៉ាត់ (KAS)
២០. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
២១. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
២២. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ
២៣. ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (DMC)
២៤. សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)សហភាពអ៊ឺរ៉ុប
២៥. សហភាពអ៊ឺរ៉ុប (EU)
២៦. ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ស៊ុយអែត (SIDA)